ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# លទ្ធផលនៃការពិនិត្យការអនុវត្តចំណូលថវិកា ប្រចាំត្រីមាសទី៣ ឆ្នាំ២០២៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២២/០១២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ បានប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។ នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងចំណូលឆ្នាំ២០២៣ សរុបមានចំនួន៣៩ ៤៩០,៤ លានរៀល ក្នុងនោះ ៖

(**ក**)-**រដ្ឋបាលកណ្តាល៖** បានគ្រោងចំណូលសរុបចំនួន៣៩ ៤៨៩ លានរៀល ចំណូលនេះរួមមាន ៖

(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន២២ ៩០៧ លានរៀល ស្មើនឹង១០៩,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ (២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវាមានចំនួន១៤ ៧៨២ លានរៀល ស្មើនឹង១១៥,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ (៣)ចំណូលពីផាកពិន័យ និងការដាក់ទណ្ឌកម្មមានចំនួន១ ៨០០ លានរៀល ស្មើនឹង៥៤,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២។

(**ខ**)-**មន្ទីររាជធានី ខេត្ត៖** បានគ្រោងចំណូលសរុបចំនួន១,៤ លានរៀល ស្មើនឹង១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ចំណូលនេះបានពីការជួលដីទំនេរនៃផលទុនពីការជួលដីទំនេរ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ

## II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ នៅក្នុងត្រីមាសទី៣ ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ អនុវត្តប្រមូលចំណូលសរុបមានចំនួន១១ ៩២៨,៤ លានរៀល ស្មើនឹង៣០,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១២៦,៣% ធៀបនឹងកម្មវិធីដែលបានដាក់ចេញក្នុងនោះ ៖

(**ក**)-**រដ្ឋបាលកណ្តាល៖** អនុវត្តប្រមូលចំណូលសរុបចំនួន១១ ៩២៨,៤ លានរៀល ស្មើនឹង៣០,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១២៦,៣% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ចំណូលនេះរួមមាន ៖

(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន៦ ៦២៣,៩ លានរៀល ស្មើនឹង២៨,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១២៦,០% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវាមានចំនួន៤ ០៧១,១ លានរៀល ស្មើនឹង២៧,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១០៨,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៣)ចំណូលពីផាកពិន័យ និងការដាក់ទណ្ឌកម្មមានចំនួន៦៦២,៧ លានរៀល ស្មើនឹង៣៦,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១២៥,០% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៤)ផលហិរញ្ញវត្ថុមានចំនួន៩,០ លានរៀល ដែលជាចំណូលបានមកពីការបង់សំណោសចំណាយបៀវត្ស និង(៥)ផលពិសេសផ្សេងៗ

មានចំនួន៥៦១,៧ លានរៀល (បានមកពីការដោះដូរទីតាំង មជ្ឈមណ្ឌលអភិវឌ្ឍន៍ពិពិធកម្មដំណាំស្រូវ ចម្ការឈើអង្គព្រលឹង និងនាយកដ្ឋានកសិឧស្សាហកម្ម ចំនួន ៤៤២,៤ លានរៀល និងបង់ប្រាក់សល់ពីការបិទគម្រោង MIWRM របស់រដ្ឋបាលជលផលចំនួន១១៩,៣ លានរៀល)។

(ខ)-**មន្ទីររាជធានី ខេត្ត៖** មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺមិនទាន់បានអនុវត្តចំណូលពីការជួលដីទំនេរទេ។

III-**ទិសដៅអនុវត្តបន្ត**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តខិតខំនិងជំរុញការប្រមូលចំណូលបង់ចូលថវិកាជាតិស្របទៅតាមកម្មវិធីចំណូលប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់សរុប៧ ៩១៨,៥ លានរៀល។ បន្តអនុវត្តកិច្ចសម្របសម្រួល និងសហការជាមួយអង្គភាពប្រមូលចំណូល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរៀបចំប្រកាសអន្តរក្រសួង និងឯកសារកែសម្រួលសេវាសាធារណៈ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

III-**សេចក្តីសន្និដ្ឋាន**

សរុបសេចក្តីមកការអនុវត្តប្រមូលចំណូលប្រចាំត្រីមាសទី៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចបាន១២៦,៣% ធៀបទៅនឹងកម្មវិធីដែលបានដាក់ចេញពោលលើសផែនការ២៦,៣% ករណីនេះបណ្តាល មកពីការអនុវត្តប្រមូលចំណូលថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ចមានកំណើនក្នុងត្រីមាសទី៣ ពោលកើន១៤៨.៤% ធៀបនឹងផែនការដាក់ចេញ ការបង់ថ្លៃឈ្នួលចម្ការកៅស៊ូកើនឡើង (ទិន្នផលកើនឡើង) ២១២% ធៀបនឹងផែនការ និងបានការដោះដូរទីតាំងមជ្ឈមណ្ឌលអភិវឌ្ឍន៍ពិពិធកម្មដំណាំស្រូវ ចម្ការឈើអង្គព្រលឹង និងនាយកដ្ឋានកសិឧស្សាហកម្ម ចំនួន ៤៤២,៤ លានរៀល និងបង់ប្រាក់សល់ពីការបិទគម្រោង MIWRM របស់រដ្ឋបាលជលផលចំនួន១១៩,៣ លានរៀល)។

ដូច្នេះដើម្បីអនុវត្តប្រមូលចំណូលឱ្យបានតាមផែនការឆ្នាំ២០២៣ អង្គភាពពាក់ព័ន្ធទទួលបន្ទុកប្រមូលចំណូលត្រូវបន្តការយកចិត្តទុកដាក់ក្នុងការប្រមូល និងបង់ចំណូលឱ្យបានទាន់ពេលវេលា គួបផ្សំនឹងប្រតិបត្តិតាមនីតិវិធីថ្មីៗពាក់ព័ន្ធការបង់ចំណូលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ថ្ងៃច័ន្ទ ៣រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២៣

**រដ្ឋលេខាធិការ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**គីម សុន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
## ស្តីពី
## លទ្ធផលនៃការពិនិត្យការអនុវត្តចំណាយថវិកា ប្រចាំត្រីមាសទី៣ ឆ្នាំ២០២៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### សេចក្តីផ្តើម

ឆ្នាំ២០២៣ គឺជាឆ្នាំទី៨ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តថវិកាកម្មវិធីពេញលេញដោយឈរលើគោលបំណងគោលនយោបាយរួមមួយគឺ៖ "**ជំរុញកំណើនកសិកម្មប្រកបដោយភាពប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព**"។ ដើម្បីឈានទៅសម្រេចគោលបំណងនេះ ក្រសួងបានដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់ អនុវត្តជាកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពទៅតាមផ្នែកជំនាញនៃអង្គភាពថវិកាទាំង៤៦អង្គភាព ក្នុងនោះថ្នាក់កណ្តាល មានចំនួន២១ អង្គភាពថវិកា និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានចំនួន២៥ រាជធានី ខេត្ត។

### I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២២/០១២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ បានប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។ នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងចំណាយឆ្នាំ២០២៣ សរុបមានចំនួន២៨០ ៧៦៨ លានរៀល ក្នុងនោះ ៖

**(ក)-រដ្ឋបាលកណ្តាល៖** បានគ្រោងឥណចំណាយសរុបចំនួន១៧៩ ១៧៧ លានរៀល រួមមាន៖

- ឥណទានចំណាយថវិកាចរន្ត មានចំនួន ១៦៤ ១៧៧ លានរៀល
- ឥណទានចំណាយថវិកាមូលធន មានចំនួន ១៥ ០០០ លានរៀល

**(ខ)-មន្ទីររាជធានី ខេត្ត ៖** បានគ្រោងឥណទានចំណាយថវិកាចរន្តសរុបចំនួន១០១ ៥៩១ លានរៀល។

### II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ នៅក្នុងត្រីមាសទី៣ ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ អនុវត្តចំណាយតាមអាណត្តិបើកប្រាក់សរុបចំនួន៧០ ៦៦១,៤ លានរៀល ស្មើនឹង២៥,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១០២,៤% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ក្នុងនោះ ៖ រដ្ឋបាលកណ្តាល អនុវត្តបានចំនួន៤២ ០០៣,៨ លានរៀល ស្មើនឹង២៣,៤% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៩៩,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ រីឯមន្ទីររាជធានី ខេត្ត អនុវត្តបានចំនួន២៨ ៦៥៧,៦ លានរៀល ស្មើនឹង២៨,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១០៦,៤% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(ក)-រដ្ឋបាលកណ្តាលៈ

ដោយពិនិត្យទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថា ការអនុវត្តចំណាយតាមអាណត្តិបើកប្រាក់របស់រដ្ឋបាលកណ្តាល (២១ អង្គភាពថវិកា) សម្រេចបានចំនួន៤២ ០០៣,៨ លានរៀល ដោយក្នុងនោះ (ក)ការទិញ (ជំពូក៦០) អនុវត្តបានចំនួន៦ ៤៨៩,០ លានរៀល ស្មើនឹង៣០,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង ៥៥,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន៦ ៣៥៧,៥ លានរៀល ស្មើនឹង ១៧,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១១៤,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ពន្ធនិងអាករ (ជំពូក៦៣) អនុវត្តបានចំនួន៨២,១ លានរៀល ស្មើនឹង៣១,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង៩៥,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ)បន្ទុកបុគ្គលិក (ជំពូក៦៤) អនុវត្តបានចំនួន២៣ ៤២៩,៥ លានរៀល ស្មើនឹង ២៩,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១១៦,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ)ឧបត្ថម្ភធន (ជំពូក៦៥) អនុវត្តបានចំនួន៤ ៨៦១,៥ លានរៀល ស្មើនឹង១៩,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង ១២៦,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ង)ចំណាយមូលធន (ជំពូក២១) អនុវត្តបានចំនួន៧៨៤,២ លានរៀល។

ម្យ៉ាងវិញទៀត ដោយពិនិត្យលើចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់អង្គភាពរដ្ឋបាលកណ្តាល ឃើញថាទឹកប្រាក់សរុបចំនួន៤២ ០០៣,៨ លានរៀល នេះត្រូវបានអនុវត្តចំណាយសម្រាប់ ៖

(១) ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច (កម្មវិធីទី១) ចំនួន៣ ៩០៣,៣ លានរៀល ស្មើនឹង១០,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

(២) ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ (កម្មវិធីទី២) ចំនួន៦ ២៥៨,៤ លានរៀល ស្មើនឹង ៥៣,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

(៣) ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម (កម្មវិធីទី៣) ចំនួន១ ៩៤៧,១ លានរៀល ស្មើនឹង២៣,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

(៤) ការគ្រប់គ្រងនិងអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ (កម្មវិធីទី៤) ចំនួន១ ២០៦,២ លានរៀល ស្មើនឹង២៧,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣

(៥) ការគ្រប់គ្រងស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស (កម្មវិធីទី៥) ចំនួន២៨ ៦៨៨,៨ លានរៀល ស្មើនឹង២៣,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣។

(ខ)-មន្ទីររាជធានី ខេត្ត ៖

យោងតាមការពិនិត្យការអនុវត្តចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង២៥រាជធានី ខេត្ត បានអនុវត្តចំណាយថវិកាតាមអាណត្តិបើកប្រាក់សរុបមានចំនួន២៨ ៦៥៧,៦ លានរៀល ស្មើនឹង២៨,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១០៦,៤% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ក្នុងនោះចំណាយលើ (ក) ការទិញ (ជំពូក៦០) អនុវត្តបានចំនួន២ ៨៦៨,៩ លានរៀល ស្មើនឹង២៥,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១៤០,៦% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន៨ ៧១៦,៨ លានរៀល ស្មើនឹង៣៧,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង១០១,០% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ)បន្ទុកបុគ្គលិក (ជំពូក៦៤) អនុវត្តបានចំនួន១៤ ៦០០,២ លានរៀល ស្មើនឹង២៤,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង ៩៦,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ)អត្ថប្រយោជន៍សង្គម អនុវត្តបានចំនួន២ ៤៤៩,៤ លានរៀល ស្មើនឹង៣៣,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣ ឬស្មើនឹង២២៣,៨% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ង) ជំពូក៦៣ (ពន្ធនិងអាករ) អនុវត្តបាន២២,៣ លានរៀល ស្មើនឹង៣០,៥% ឬស្មើនឹង៣៩,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

III-**បញ្ហាប្រឈម**

យោងតាមការអធិប្បាយខាងលើឃើញថា ការអនុវត្តចំណាយថវិកាប្រចាំត្រីមាសទី៣ ឆ្នាំ២០២៣ សម្រេចបានល្អប្រសើរធៀបនឹងកម្មវិធីដែលបានដាក់ចេញ ដោយសារអង្គភាពថវិកាទាំងអស់យល់ដឹងតាមប្រកាស សារាចរណែនាំ និងនីតិវិធីថ្មីៗ បានដាក់ចេញនាពេលកន្លងមក។

ទន្ទឹមនឹងនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នូវតែជួបបញ្ហាប្រឈមមួយចំនួនដែលធ្វើឱ្យដំណើរការចំណាយមានការយឺតយ៉ាវខ្លះៗ ទាំងចំណាយចរន្តនិងចំណាយមូលធន ដែលបញ្ហាលំបាកទាំងនោះមានដូចជា ៖

- ការផ្តល់សាច់ប្រាក់បើកមុនមានភាពយឺតយ៉ាវប្រើពេលវេលាយូរ ធ្វើឱ្យអង្គភាពមិនមានសាច់ប្រាក់មុនទៅបំពេញភារកិច្ច
- ការផ្តល់បុរេប្រទានជូន៦០% នៃសំណើសុំ ធ្វើឱ្យមានការលំបាករកថវិកា៤០% ពីប្រភពផ្សេងយកមកធ្វើសកម្មភាព ការផ្តល់នេះមិនឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងរបស់ការងារ។

IV-**ទិសដៅអនុវត្តបន្ត**

អង្គភាពថវិកានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងខិតខំអនុវត្តចំណាយថវិកាក្នុងការធ្វើសកម្មភាពការងារដើម្បីសម្រេចបានសូចនាកររបស់ខ្លួនទៅតាមកម្មវិធីចំណាយប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់សរុបចំនួន៦១ ៩០៥,៤ លានរៀល ក្នុងនោះ (១)រដ្ឋបាលកណ្តាល ចំនួន៦០ ៧៩២,២ លានរៀល (២) មន្ទីររាជធានី-ខេត្ត ចំនួន១ ១១៣,២ លានរៀល។

V-**សេចក្តីសន្និដ្ឋាន**

សរុបសេចក្តីមកការអនុវត្តចំណាយថវិកាតាមអាណត្តិបើកប្រាក់ប្រចាំត្រីមាសទី៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចបានលទ្ធផលល្អប្រសើរ។

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ខែតុលា ឆ្នាំ២០២៣

**រដ្ឋលេខាធិការ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

គឹម សុន